# ក្អែក និង ហង្ស
# ជ្រូក និង ទន្សាយ
# ក្អែក និង ពស់

LIBRARY



N. 73 CRAW AND SWAN

០៥០.
៣២៦

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

www.budinst.gov.kh        www.elibraryofcambodia.org

# រឿង ក្អែក និង ហង្ស
# ក្រអ៊ូក និង ចន្ទ្រាយ
# ក្អែក និង ពស់

LIBRARY
BUDDHIST INSTITUTE
៤៣៨១៤៤

ដកស្រង់ដោយ៖ ខាត់ សឿន
កែសម្រួលដោយ៖ នង់ ផារី (វិណ្ណា)
រចនាអក្សរដោយ៖ លត់ វ៉ាន
កែវ សារឿន (ឃុន)
រចនារូបភាពដោយ ឃុន សារី
វ៉ាយ សាវេន

ឧបត្ថម្ភនិងបោះពុម្ពផ្សាយដោយអង្គការស្សូតូស្យុជប៉ុន
(J.S.R.C.)

# រឿង ក្អែក និង ហង្ស

នៅតាមផងផ្លូវទៅកាន់រាជធានី មានឈើមួយដើម យ៉ាងធំ ប្រកបដោយមែកសាខា ចោលម្លប់ត្រឈឹងត្រឈៃ ហើយមានសត្វក្អែកមួយអាស្រ័យនៅទីនោះ ។ ថ្ងៃមួយ មានព្រានព្រៃម្នាក់ប្រដាប់ដោយធ្នូនិងព្រួញ កំពុងស្វែងរកបរបាញ់សត្វ ដើម្បីលក់ចិញ្ចឹមជីវិត ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

- ការដើរបរបាញ់របស់ព្រានកាន់តែឆ្ងាយ ហើយថ្ងៃក៏កាន់តែខ្ពស់ ការហាត់ហេវកកើតមាន ដល់ក្រឡេកទៅឃើញដើមឈើធំ មានម្លប់ត្រជាក់ស្រួលក៏ដើរចូលទៅ ហើយដាក់ធ្នូនិងស្នាផ្អែកគល់ឈើ ក៏ប្រះខ្នងដេកលក់ក្រោមដើមឈើនោះទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកសត្វក្អែកដែលអាស្រ័យនៅទីនោះ ដែលជាសត្វមានចិត្តអាក្រក់ ភាពជាទុជ៌ន តែងតែមានចិត្តប្រណែនមិនឲ្យសត្វដទៃបានសេចក្តីសុខ លុះឃើញព្រានអេកស្របហមាត់ធ្លុង ក៏បន្ទោរបង់អាចម៍របស់ខ្លួនទៅក្នុងមាត់ព្រាន ហើយក៏ហើរគេចចេញពីទីនោះទៅ

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

នៅលើវេហាស៍ មានសត្វហង្សមួយកំពុងហើរហេរ ដោយពេលនោះព្រះសូរ្យក៏ជ្រៀងជ្រេដែរ ហង្សក្រឡេកឃើញកំដៅថ្ងៃចាំងមកលើព្រានក៏កើតមានចិត្តមេត្តាសន្តោសក៏បានហើរបន្ទាបខ្លួនពីលើវេហាស៍ ចុះមកទំលើមែកឈើត្រដាងស្លាបដើម្បីបាំងកំដៅព្រះសុរិយា ដោយមនោគតិប្រកបដោយករុណា ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

រីឯព្រានដែលកំពុងអស់កម្លាំង បានមួយព្រួញដាក់ស្រែល លាយឡំនឹងខ្យល់បក់មករំភើយៗផងនោះ ក៏ដេកលក់ស៊ប់ លុះភ្ញាក់ដំណេកហើយក៏ស្ទុះក្រោកឡើង ស្រាប់តែឃើញអាចម៍ពេញក្នុងមាត់ ពេលនោះភ្លើងទោសៈមោហៈសាបសេះពេញទិវា ក្រឡេកគេត្រាចៅឃើញហង្សកំពុងតែទំត្រដាងស្លាប ដោយអំណាចភ្លើងទោសៈ ក៏កន្ត្រាក់ធ្នូលើកបាញ់ប្រហារហង្សស្លាប់ភ្លាមមួយរំពេច ។

អនិច្ចាសត្វហង្សត្រូវស្លាប់យ៉ាងអាណោចអាធម្មគួរឲ្យអាសូរ ។

ស្រះកែវថ្ងៃទី 14 / 8 / 1982

អ្នកស្រង់ដោយ ខាក់សៀន

កែសម្រួលដោយ គង់_គារី (វិណ្ណា)

www.budinst.gov.kh www.elibraryofcambodia.org

# រឿង ក្អែក និង ពស់

( អ្នកមានប្រាជ្ញាអាចញ៉ាំង អ្នកដទៃឲ្យសម្លាប់សត្រូវរបស់ខ្លួនបាន )

នៅក្នុងទីវាលមួយដ៏ធំល្វឹងល្វើយ ឆ្ងាយដាច់ស្រយាលពីស្រុកភូមិ ហើយមានដើមឈើមួយដើមយ៉ាងធំស្កុះនៅក្នុងទីវាលនោះ មានមែកសាខាជាទីស្នាក់អាស្រ័យនៃក្អែក ញីឈ្មោលមួយគូព្រមទាំងកូន ហើយនៅត្រង់គល់មានពស់មួយធ្វើរន្ធនៅនឹងដើមឈើនោះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

ពេលក្អែកញី ឈ្មោលចេញទៅស្វែងរកចំណីមកចិញ្ចឹមកូនបាត់ ពស់ក៏វារឡើងទៅលេបស៊ីកូនក្អែកទាំងនោះ , ពេលពស់កំពុងតែលេបកូនក្អែក ស្រាប់តែក្អែកញីបានហើរមកដល់ តែមិនដឹងធ្វើដូចម្តេច ដើម្បីជួយកូនឲ្យផុតពីពស់បាន គឺគ្រាន់តែហើរឆាបចុះឆាបឡើង ទាំងចិត្តក្តុកក្តួលអាណិតកូនសម្លាញ់ ។

www.budinst.gov.kh www.elibraryofcambodia.org

ពេលនោះគេចេះតែគន្លងទៅ ក្អែកញីក៏កកលនឹងពាង ទៀតក៏និយាយទៅកាន់ក្អែកឈ្មោលថា៖

- អ្នកបងជាទីពឹងនឹង យើងគួរលះបង់ចេញចាកដើមឈើនេះទៅ ដើម្បីរកឈើថ្មីធ្វើជាទីអាស្រ័យ ព្រោះដើមនេះប្រកបដោយគ្រោះថ្នាក់ អន្តរាយកូនចៅ គេទៅយើងមុខជាអស់មានពូជពង្ស

- នែអូនសម្លាញ់ កុំគុញចប់អ្វី រឿងនេះទុកឲ្យបង កំហុសធំៗនៃពស់ច្រើនគ្រាណាស់មកហើយ ម្តងនេះបងពុំអាចទ្រាំតទៅទៀតបានទេ .

- ចុះបងធ្វើដូចម្តេចទៅ បើពស់មានកម្លាំងជាងយើង

- ថ្វីត្បិតតែយើងមានកម្លាំងតិចមែន តែយើងរកឧបាយសម្លាប់ពស់ឲ្យបាននៅពេលខាងមុខនេះ ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

នៅមិនឆ្ងាយប៉ុន្មានពីដើមឈើនេះ មានស្រះមួយ មនុស្សទាំងឡាយតែងនាំគ្នាមកងូតទឹកស្រះនេះលេងកំសាន្ត មុននឹងចុះលេងទឹក មនុស្សទាំងនោះបានដោះសម្លៀកបំពាក់ខ្សែក ចិញ្ចៀន ដាក់នៅមាត់ស្រះ ហើយនាំគ្នាចុះលេងទឹកយ៉ាងសប្បាយ តាមមនោសញ្ចេតនារម្មណ៍របស់គេគ្រប់គ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

ក្អែកឈ្មោល ក្រោយពីបានឃើញមនុស្សកំពង់តែលេងទឹកក្នុងស្រះយ៉ាងសប្បាយ ហើយទុកសម្លៀកបំពាក់និងអលង្ការនៅនឹងមាត់ស្រះ ក៏ហើរមកពាំខ្សែកពីលើសម្លៀកបំពាក់សំដៅទៅលំនៅរកត្ម លុះដល់កន្លែងហើយក៏យកខ្សែកនោះទៅដាក់នៅមាត់រូងរបស់ពស់ ។

www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

មនុស្សដែលកំពុងលេងទឹក ក្រឡេកមកឃើញក្អែកពាំខ្សែករបស់ខ្លួនក៏នាំគ្នាឡើង ហើយប្រាប់គ្នាថា៖ ក្អែកពាំខ្សែកឥឡូវហើរទៅទំនៅលើដើមឈើធំនោះ ៗ ក្រោយពីដឹងដំណឹងហើយមនុស្សទាំងនោះក៏នាំគ្នាទៅ ដោយនូវដៃមានកាន់ដំបងទៅជាមួយផងដើម្បីប្រហារក្អែក ដែលពាំខ្សែកខ្លួន ៗ

www.budinst.gov.kh www.elibraryofcambodia.org

ពេលមនុស្សនាំផ្លូវយកទៅដល់ ក៏ឃើញខ្សែករបស់ខ្លួននៅនឹងមាត់រន្ធពស់ ចំណែកពស់គ្រាន់តែព្រួសមាត់មនុស្សក៏ចេញមក តែអកុសលសត្វពស់កំណាចត្រូវពួកមនុស្សវាយនឹងដំបងស្លាប់បាត់ទៅ ទើបគេយកខ្សែកដើរត្រឡប់មកមាត់ស្រះវិញ ជនប្រព្រឹត្តអាក្រក់តែងតែទទួលផលដូចពស់នេះឯង ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org




www.budinst.gov.kh www.elibraryofcambodia.org

ក្រោយពីពស់កំណាចស្លាប់បាត់បង់ទៅ ភាពរស់នៅដោយសុខសាន្តរបស់ក្អែកញីឈ្មោល បានកើតមានឡើងវិញហើយលែងមានសត្វអ្វីមកយាយីភាពសុខសាន្តរបស់វាបានទៀតហើយ ។ ក្អែកទាំងពីរបានសុខសាន្ត ក៏មកពីបញ្ញារបស់ខ្លួនដូចនេះហើយ បានជាបុរាណយើងលើកឡើងថា៖
( បញ្ញាជាទ្រព្យធម្មួយយ៉ាងប្រសើររបស់មនុស្ស និង សត្វ )

និពន្ធដោយ ខាន់ សៀន
កែសម្រួលដោយ នង់ ផារី (វណ្ណ)

**ចប់**

* * *

www.budinst.gov.kh www.elibraryofcambodia.org

# រឿង ដំរី និង ទន្សាយ

( សត្វតូចអាចឈ្នះសត្វធំបានដោយឧបាយកល )

នៅក្នុងគិម្ហរដូវ ជារដូវមួយរាំងរីងស្ងួតហួតហែង ដោយអំណាចនៃសែងសូរ្យ ស្លឹករុក្ខជាតិទាំងឡាយក្រៀមស្វិតស្រពោន រីឯសត្វផងទាំងឡាយក៏បលាចល ខ្វាយខ្វល់ពេញព្រឹក្សាដោយសារការអត់ទឹក ។ ថ្ងៃមួយដំរីមួយហ្វូងបានដើរសំដៅទៅកន្លែងអ្នកដឹកនាំខ្លួន ទើបនិយាយថា លោកជាទីពឹង ត្រពាំងទាំងឡាយរីងស្ងួតហួតអស់រលីងហើយ យើងទាំងអស់គ្នាពុំអាចរស់នៅបានដោយគ្មានទឹកដែរ តើលោកមានមធ្យោបាយយ៉ាងណាដែរ ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

ពេលនោះមេដឹកនាំជ្រូក ក៏មិនចេញស្តីមួយម៉ាត់ឡើយ ហើយក៏នាំហ្វូងជ្រូកទាំងអស់ធ្វើដំណើរចេញទៅដើម្បីស្វែងរកទឹក ។ ហ្វូងជ្រូកធ្វើដំណើរកាន់តែឆ្ងាយទៅៗ ក៏បានទៅដល់ត្រពាំងមួយដែលមានទឹកថ្លាឆ្វង់ មច្ឆាទាំងឡាយកំពុងតែលោតលេងយ៉ាងសប្បាយ ។

នៅក្បែរមាត់ត្រពាំងនោះ មានសត្វទន្សាយជាច្រើនរស់នៅ ដល់ឃើញហ្វូងជ្រូក ក៏មានការភ្ញាក់ផ្អើលរត់ប្រញាប់រកកន្លែងលាក់ខ្លួនបំពានគ្នា ក្រែងជ្រូកទាំងនោះជាន់បាត់បង់ជីវិត ។ ខ្លះតែមិនទាន់ក៏ត្រូវហ្វូងជ្រូកជាន់ស្លាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងចំណោមសត្វទន្សាយដែលរត់ ដោយភ័យអំពីហ្វូងសត្វព្រែក មានសត្វទន្សាយមួយរាងធំហើយមានចំណាស់ជាងគេ មិនព្រមរត់ទៅណាទេ នៅអង្គុយគិតម្នាក់ឯងថា ព្រឹត្តិការណ៍អន្តរាយដែលកើតមានដល់ពពួកទន្សាយនាពេលនេះ ខ្លាំងជាងពេលណាទាំងអស់ បើអញរត់ចេញទៅដែរ តើបានអ្នកណាដើម្បីឈមមុខដោះស្រាយរឿងនេះ ដូច្នេះមានតែអញ ព្រោះរឿងនេះគឺរឿងរបស់ពពួកអញ លុះគិតឃើញដូច្នេះហើយ ទន្សាយក៏ដើរសំដៅទៅកាន់ហ្វូងព្រែក ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

ពេលទន្សាយធ្វើដំណើរទៅដល់ ក៏ឈរលើគល់ឈើលើកដៃចង្អុលទៅហ្វូងក្រពើ ព្រមទាំងបញ្ចេញវាចាថា នែម្នាលក្រពើទាំងអស់ ! ឯងមកដេកគគៀលធ្វើឲ្យល្អក់ទឹកត្រពាំងអញអស់ មិនតែប៉ុណ្ណោះទេ ថែមទាំងដាក់សម្លាប់ពួកទន្សាយ ដែលជាពូជពង្សនឹងក្រុមញាតិរបស់អញស្លាប់ទៀត តែពួកឯងទាំងអស់ត្រូវដឹងថា ត្រពាំងនេះជារបស់យើង ព្រោះព្រះចន្ទ្របានចាត់ពួកយើងឲ្យមកថែរក្សា ឯងធ្វើនេះមិនត្រឹមត្រូវតាមច្បាប់ទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ហ្វូងក្រួកទាំងអស់ដែលកំពុងតែសប្បាយនត្រៀលលេងក្នុងត្រពាំង ដោយខ្លួនដាច់ទឹកមកជាយូរហើយនោះ ដល់ឮសម្ដីទន្សាយថា ភ្ញាក់ស្រឡាំងកាំង ទើបមេដឹកនាំក្រួកឡើងមកសួរទន្សាយថា តើព្រះឥន្ទ្រនោះឈ្មោះអីនៅទីណា? ទន្សាយឆ្លើយថា អញទៅហៅគ្នាទាំងអស់មកយើងនឹងថ្លែងប្រាប់ ដើម្បីឲ្យបានដឹងទាំងអស់គ្នា ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

អោយឃើញអាការៈដូច្នេះ ទន្សាយខ្លះក៏រត់មកវិញ ។ ពេលដំរីឡើងមកដល់ហើយ ទន្សាយឈរលើគល់ឈើថ្លែងប្រាប់ដំរីថាយើងទន្សាយ ព្រះចន្ទមានបុណ្យលោកប្រើឲ្យមកថែរក្សាទឹកនេះ ឥឡូវពួកឯងធ្វើនេះមិនត្រូវតាមច្បាប់ទេ ។ មេដឹកនាំដំរីក៏និយាយទាំងភ័យញ័រថា លោកជាអ្នកថ្លែងសេចក្តី យើងទាំងអស់គ្នាមិនដឹងដូច្នេះចាប់ពីពេលនេះទៅយើងឈប់ធ្វើដូច្នេះទៀត ។ ទន្សាយនិយាយសំឡុតទៀតថា ដើម្បីកុំឲ្យព្រះចន្ទទ្រង់ពិរោធចូរឯងថ្វាយបង្គំសុំទោសទន្សាយមួយដែលនៅពីមុខយើងសិន សឹមត្រឡប់ទៅវិញ ។

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

ហ្វូងក្រួចទាំងអស់ក៏នាំគ្នាអង្គុយលើកជើងមុខឲប្រណាម្យ និយាយអង្វរថា បពិត្រទេវៈ ក៏ហុសទាំងឡាយដែលយើងខ្ញុំទាំងអស់បានប្រព្រឹត្តកន្លងរួចមកហើយ សូមលោកម្ចាស់អភ័យទោសឲ្យយើងខ្ញុំទាំងអស់គ្នាផង យើងទាំងអស់គ្នាសម្រេចចិត្តថា លែងមកកាន់ទីនេះទៀតហើយ ។ ទន្សាយអភ័យទោសឲ្យក្រួចហើយ ទើបបង្គាប់ឲ្យក្រួចថយចេញទៅ ក្រោយពីពេលដែលទន្សាយបានអភ័យទោសរួចហើយ ។ ទន្សាយជាសត្វតូចមានកម្លាំងតិច តែអាចយកជំនះលើហ្វូងក្រួចដែលមានកម្លាំងខ្លាំងបាន ក៏មកពីសត្វទន្សាយមានបញ្ញាវៃអះ ។

ស្រះកែវថ្ងៃទី ១៧-៨-១៩៨២
ដកស្រង់ដោយ ខាត់ ស្មៀន
កែសម្រួលដោយ នង់ ឥារី (វណ្ណា)

www.budinst.gov.kh www.elibraryofcambodia.org

- ជិតចេញផ្សាយហើយ -

សូមអស់លោកអ្នកនាងរង់ចាំអាន រឿង វិមានយក្ខពាង ជាខ្សែរឿងយុទ្ធគុនបុរាណដែលប្រកបដោយសាកប្បយុទ្ធ យ៉ាងស៊ីសាច់ហុតឈាម និងចេញផ្សាយនៅពេលឆាប់ៗនេះ ៗ

សូមអរគុណ

និពន្ធដោយ -:- ជិតសុគុន -:-

www.budinst.gov.kh www.elibraryofcambodia.org

# វីរបុរសឆ្កាព



ឧបត្ថមដោយ

# J S R C

www.budhist.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org